## អនុក្រឹត្យ លេខ ៥០ អនក្រ.បក

### ស្ដីពីការបង្កើតកំពង់ផែស្វយ័តក្រុងព្រះសីហនុ ក.ស.ស

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើ ដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការអនុវត្តន៍ព្រះរាជក្រមស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### សំរេច

### ជំពូក ១

### បទបញ្ញត្តិទូទៅ

**មាត្រា ១.-** ត្រូវបានបង្កើតសហគ្រាសសាធារណៈ ដែលមានលក្ខណៈជាក្រុមហ៊ុនរដ្ឋឈ្មោះ " កំពង់ផែក្រុងព្រះសីហនុ " សរសេរកាត់ (ក.ស.ស) Port Autonome de Sihanouk ville ( PAS) ដែលស្ថិតក្រោមអាណាព្យាបាលក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

- គ.ស.ស មានទីស្នាក់ការនៅក្រុងព្រះសីហនុ
- គ.ស.ស គឺជានីតិបុគ្គលមានស្វ័យភាពផ្នែកបច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុ ។
- គ.ស.ស ត្រូវស្ថិតក្រោមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ហើយនិងតាមបទប្បញ្ញត្តិនៃព្រះរាជក្រម លេខ ០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ព្រមទាំងបទប្បញ្ញត្តិនៃច្បាប់ពាណិជ្ជកម្ម ។

មាត្រា ២ .- គ.ស.ស មានភារកិច្ចធ្វើអាជីវកម្ម-សេវាកម្មលើផ្នែកការងារ :

-ភ្នាក់ងារកិច្ច នាំចេញ-នាំចូល និងផ្តល់សេវាកម្មដល់នាវា

-សេវាផ្ទេរទំនិញ- ផ្ទុកនិងដឹកជញ្ជូនទំនិញ

-ការងារកំរៃជើងសារ ស្តុកទំនិញ ឃ្លាំង និងការ

-ការងារអភិវឌ្ឍន៍ និងសកម្មភាពផ្សេងទៀតស្របតាមគោលដៅ គ.ស.ស ដែលអាច ដែលត្រូវបង្កើត

មាត្រា ៣ .- គ.ស.ស មានភារកិច្ច :

-ទទួលខុសត្រូវនិងចាត់ចែងលើការងាររដ្ឋបាលបុគ្គលិក ហិរញ្ញវត្ថុ សម្ភារបរិក្ខារក្នុងតំបន់គ្រប់គ្រង ។

-ប្រកាន់តាមគោលការណ៍ និងលក្ខខណ្ឌការ ពន្ធដារនិងអាជីវករ ។

-គ្រប់គ្រងដឹកនាំ និងចាត់ចែងសកម្មភាពឲ្យមានប្រសិទ្ធភាព និងមានការរីកចំរើន ។

-ក្នុងករណីជាស្ថាប័នសាធារណៈ គ.ស.ស ទទួលបំពេញ ផ្សព្វផ្សាយ និងភារកិច្ចទាំងឡាយ ដើម្បីបំពេញសកម្មភាពតាមកម្មវត្ថុរបស់ខ្លួន ។

មាត្រា ៤.- ដើមទុនចុះបញ្ជី ពីរលាន គ.ស.ស ត្រូវរក្សាទុកនូវការគ្រប់គ្រងច្បាប់និងទ្រព្យសម្បត្តិ ជាធរមាន

មាត្រា ៥.- ដើមទុនដំបូងនៃ គ.ស.ស ត្រូវកំណត់ដោយបញ្ជីគណនេយ្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាធារណការនិងដឹកជញ្ជូន ។

-សេវាដែលអនុក្រឹត្យនេះចូលជាធរមាន គ.ស.ស ត្រូវចាត់ទុកជាកម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋ លើទ្រព្យសម្បត្តិ ដែលបានដាក់ក្នុងបញ្ជីគណនេយ្យ ។

មាត្រា ៦.- ប្រធាន គ.ស.ស ត្រូវស្ថិតក្រោមលក្ខន្តិកៈដោយឡែក ដោយក្រុមប្រឹក្សាភិបាល ដោយផ្អែកលើព្រះរាជក្រម ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។ ចាប់ពីពេលដែលលក្ខន្តិកៈដោយឡែកនេះចូលជាធរមាន បុគ្គលិកទាំងអស់របស់ គ.ស.ស មិនស្ថិតក្នុងក្របខ័ណ្ឌរបស់រដ្ឋតទៅទៀតទេ ។

## ជំពូក ២

## ការដឹកនាំ និងការគ្រប់គ្រង

មាត្រា ៧.- គ.ស.ស ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញមុខងារក្នុងក្របខ័ណ្ឌ នៃបទបញ្ញត្តិ អនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

www.pheakdeylaw.com

-ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម :

-តំណាងក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន ១រូប ជាប្រធាន

-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១រូប ជាសមាជិក

-តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប ជាសមាជិក

-តំណាងអាជ្ញាធរក្រុងព្រះសីហនុ ១រូប ជាសមាជិក

-តំណាងក្រសួងពាណិជ្ជកម្ម ១រូប ជាសមាជិក

-តំណាងនិយោជិតរបស់ ក.ស.ស ១រូប ជាសមាជិកស្ម័គ្រប្រវត្តិ

-អគ្គនាយក ក.ស.ស ១រូប ជាសមាជិក

**មាត្រា ៨.-** សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ ដែលបានធ្វើការងារយ៉ាងតិច ០៥ (ប្រាំឆ្នាំ) ឬជាជនស៊ីវិល ដែលមានអាយុយ៉ាងតិចពី ២៥ ឆ្នាំ និងមានបទពិសោធន៍ ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិស្វកម្ម ឬនីតិកម្ម ដែលមានសញ្ជាតិខ្មែរ និង ពុំដែលមានទោសព្រហ្មទណ្ឌ ត្រូវបានតែងតាំង ពីគណៈរដ្ឋមន្ត្រី ។

-សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះអាច បញ្ចប់មុនកំណត់ពេលវេលា និងអាចបន្តបន្ទាប់ទៀតបាន ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬ អាជ្ញាធរដែលខ្លួនតំណាងឲ្យ ។

-តំណាងនិយោជិត ត្រូវជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោមនិយោជិត ក.ស.ស ។

**មាត្រា ៩.-** ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីតំណាងឲ្យ ក.ស.ស ក្នុងការគ្រប់គ្រងចាត់ចែង រាល់ សកម្មភាពផ្សេងៗទាក់ទងនឹងកម្មវត្ថុ របស់សហគ្រាសស្របតាមច្បាប់ជាធរមាន ជាអាទិ៍ៈ

១- ផ្តល់ការយល់ព្រមលើផែនការសហគ្រាស ដូចមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យនេះ ។

២- វាយតម្លៃលើផែនការប៉ាន់ប្រមាណ ប្រតិបត្តិការដែលបានស្នើឡើង ព្រមទាំងធ្វើវិសោធនកម្ម ដើម្បីកែ សម្រួលឲ្យបានសមស្របតាមស្ថានការណ៍ ។

៣- ផ្តល់ការយល់ព្រមលើថវិកា និងគណនីប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ក.ស.ស

៤- តាមដានសកម្មភាពរបស់អគ្គនាយក អ្នកតំណាងខ្លួន និងការបញ្ជាទិញរបស់សហគ្រាស ព្រម ទាំងលក្ខន្តិកៈនិងកាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ សម្រាប់បុគ្គលិក ដោយ អនុលោមតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យា និង អនុសញ្ញាដែល ក.ស.ស ជាភាគីត្រូវចុះហត្ថលេខា ហើយនិង ដំណើរការទូទៅមានប្រយោជន៍ ក្នុងរយៈពេលជាបន្ទាន់ ស្តីពីកិច្ចសន្យា និងអនុសញ្ញា ដែលពាក់ព័ន្ធ ដោយសហគ្រាសសាធារណៈ ។

៦- សម្រេចបង្កើត បើក ឬបិទ ការិយាល័យ និងទីភ្នាក់ងារប្រតិបត្តិការរបស់ ក.ស.ស តាមការ វិនិច្ឆ័យរបស់ខ្លួន ។

៧- កំណត់លើតម្លៃឈ្នួលពាក់ព័ន្ធនិងការធ្វើអាជីវកម្ម សេវាកម្ម លើកំពង់ផែ ។

www.pheakdeylaw.com

**មាត្រា ១០.-** ក្រុមប្រឹក្សាភិបាល បើកសម័យប្រជុំធម្មតា យ៉ាងហោចណាស់ម្តងរៀងរាល់ត្រីមាស តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើនៃសមាជិកដែលមានចំនួនយ៉ាងតិចពាក់កណ្តាល នៃចំនួនសមាជិកទាំងអស់ ។

នេះជាលើកលែងតែក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច១ ដងក្នុងរយៈពេលបីខែ ។

ក្នុងករណីមានអាសន្នៈ ត្រូវប្រជុំដោយសមាជិកណាម្នាក់ដែលមានវត្តមាន ជាអាទិ៍ ដើម្បីពិភាក្សាប្រជុំ ។

ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយ ដែលចែងក្នុងរបៀបវារៈប្រជុំ ។ របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារពាក់ព័ន្ធនឹងបញ្ហា ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរាជរដ្ឋាភិបាល យ៉ាងតិច ១០ថ្ងៃ មុនពេលបើកសម័យប្រជុំ ។

-កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមាន សមាជិក លើសពីពាក់កណ្តាល ។ បើសិនជាពុំគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ ១៥ ថ្ងៃទៀត ដើម្បីពិភាក្សាឡើងវិញ លើរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះ ពុំចាំបាច់មានកូរ៉ុមទេ ។

-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលមានប្រសិទ្ធភាព លុះត្រាតែមានការ អនុម័តដោយសំឡេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការបែកសំឡេង មានចំនួនស្មើគ្នា សំឡេងរបស់ប្រធាន ត្រូវចាត់ទុកជាសម្រេច ។

**មាត្រា ១១.-** សេចក្តីសម្រេចនៃក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុ ដែលត្រូវផ្ញើជូនក្រសួងអាណាព្យាបាល សមាជិកក្រុមប្រឹក្សាម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យ ព្រមទាំងឯកសារផ្សេងទៀត ដែលមានចែងក្នុងមាត្រា ២៥ នៃលក្ខន្តិកៈនេះ ក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីកិច្ចប្រជុំ ។ កំណត់ហេតុនេះ ត្រូវមានចុះហត្ថលេខាដោយ ប្រធានអង្គប្រជុំ និងសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ ដែលមានវត្តមានក្នុងកិច្ចប្រជុំ លើកមុននោះ ។

**មាត្រា ១២.-** អគ្គនាយក ជាអ្នកគ្រប់គ្រងសហគ្រាស ក.ស.ស និងត្រូវបានតែងតាំង តាមព្រះរាជក្រឹត្យ ស្នើដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួង អាណាព្យាបាល ។

**មាត្រា ១៣.-** ក្រុមប្រឹក្សាភិបាលត្រូវប្រគល់ភារកិច្ចទៅអគ្គនាយក ដើម្បីមាន សមត្ថភាពគ្រប់គ្រាន់ ក្នុងការគ្រប់គ្រង និងអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

ក្នុងក្របខណ្ឌនេះអគ្គនាយកត្រូវ :

១- រៀបចំឯកសារពាក់ព័ន្ធ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល និងអនុវត្តតាមសេចក្តី សម្រេចរបស់ក្រុមប្រឹក្សាភិបាល ។ តាមតំរូវការនីមួយៗ អគ្គនាយកត្រូវរាយការណ៍ជូន ក្រុមប្រឹក្សាភិបាល អំពីសកម្មភាពរបស់ ក.ស.ស ។

២- ដឹកនាំ ក.ស.ស លើផ្នែករដ្ឋបាល បច្ចេកទេស អាជីវកម្ម និងហិរញ្ញវត្ថុ ។

www.pheakdeylaw.com

៣- តំណាងឲ្យ ក.ស.ស ចំពោះមុខតតិយជនទាំងឡាយ ក្នុងការចរចាពិនិត្យលក្ខខណ្ឌកិច្ចសន្យាការ ឬពិនិត្យមើលការក្នុងក្របខ័ណ្ឌច្បាប់ និងការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

៤- មានសិទ្ធិជ្រើសរើស តែងតាំង ផ្លាស់ប្តូរតំណែង ឬបញ្ឈប់ការងារនិងមានសិទ្ធិបញ្ជាត្រួតត្រាលើបុគ្គលិក ឬមន្ត្រីគ្រប់រូប ដែលជាភ្នាក់ងាររបស់ ក.ស.ស ដោយអនុវត្តតាម (លក្ខន្តិកៈបុគ្គលិក) ឬច្បាប់ជាធរមាន និងតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

៥- មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ ក្រៅពីការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីដែលនៅក្រោមឱវាទត្រូវតាមសេចក្តីសម្រេចដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ។

តំណាងឲ្យ ក.ស.ស ចំពោះមុខតុលាការ និងគណៈកម្មការអាជ្ញាកណ្តាល ក្នុងករណីមានប្រការដែលប៉ះពាល់ដល់ ក.ស.ស និងបុគ្គលិកដទៃទៀត ។

**មាត្រា ១៤.-** ប្រាក់បៀវត្សរបស់ក្រុមប្រឹក្សាភិបាល និង ប្រាក់បំណាច់របស់អគ្គនាយកត្រូវកំណត់ដោយប្រកាសរួមក្រសួងអាណាព្យាបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៥.-** ការចុះ និងការអនុវត្តកិច្ចសន្យាលទ្ធកម្ម ក.ស.ស ត្រូវធ្វើឡើងតាមគោលការណ៍ និង នីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣
## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ១៦.-** ក.ស.ស កាន់កាប់គណនេយ្យរបស់ខ្លួនឲ្យបានត្រឹមត្រូវតាមការណែនាំគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យដែលគេទទួលស្គាល់ជាទូទៅ ។

ការិយបរិច្ឆេទគណនេយ្យ ចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល ។

តុល្យការនិងគណនី [illegible] នៅថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់ពីការិយបរិច្ឆេទ ដោយមានការត្រួតពិនិត្យគណនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។

តុល្យការនិងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនី ត្រូវដាក់ជូនការ យល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេលមិនលើសពី ១៥ថ្ងៃ រាប់ពីថ្ងៃ ដែលក្រុមប្រឹក្សាភិបាលបានពិនិត្យឯកសារទាំងឡាយ ។ ឯកសារទាំងនេះ ត្រូវបញ្ជូនទៅ ក្រសួងអាណាព្យាបាលផងដែរ ដើម្បីសុំមតិយោបល់តាមសេចក្តីដែលមានចែងក្នុងមាត្រា១៦ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

**មាត្រា ១៧.-** ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសំរាប់ អាណត្តិបីការិយបរិច្ឆេទ ។ អាណត្តិនេះអាចបន្តម្តងទៀតបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

-ប្រាក់បំណាច់សំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និង ត្រូវចំណាយក្នុងជំពូកបន្ទុកអាជីវកម្មរបស់ ក.ស.ស ។

www.pheakdeylaw.com

-[illegible] ក.ស.ស ។
[illegible] ឆ្នាំ ១៩៩៧ [illegible] ។

-[illegible] ក្រុមប្រឹក្សាភិបាល [illegible] ក្រុមប្រឹក្សាភិបាល ។

មាត្រា ១៨.- ជារៀងរាល់ឆ្នាំ មុនថ្ងៃ៣០ ខែកញ្ញា ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការតាក់តែងគម្រោងថវិកា ប្រចាំឆ្នាំ តាមសំណើរបស់អគ្គនាយក ហើយបញ្ជូនគម្រោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងអាណាព្យាបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**គំរោងប្រចាំឆ្នាំត្រូវបញ្ជាក់នូវៈ**

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានសំរាប់ចំណាយលើកម្មវិធីវិនិយោគនេះ ។

២- ថវិកាសំរាប់ដំណើរការនៃគ្រឹះស្ថាន ។

៣-តម្លៃរបស់សោធននិវត្តន៍ ពិការភាពនិងតម្លៃរបស់គ្រោះថ្នាក់ការងារ-ជម្ងឺ ស្លាប់។

៤- សេចក្ដីសន្និដ្ឋាន សំរាប់វាយតម្លៃលទ្ធផលសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ ក.ស.ស ។

មាត្រា ១៩.- ធនធានរបស់ ក.ស.ស រួមមាន :

-ប្រាក់ភាគទានដែលរដ្ឋផ្ដល់ឲ្យ (តាមច្បាប់ថវិកា នៅពេលចាំបាច់) ប្រាក់ចំណូលផ្សេងៗ ប្រាក់ចំណេញបានមកពីសកម្មភាពរបស់គ្រឹះស្ថាន ។

-ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ ក.ស.ស ។

-ប្រាក់ជំនួយ និងប្រាក់អំណោយផ្សេងៗ។

មាត្រា ២០.- ចំណាយរបស់ ក.ស.ស រួមមាន :

-ចំណាយប្រចាំសំរាប់ដំណើរការ

-ចំណាយវិនិយោគ

-សោធននិវត្តន៍

-ចំណាយផ្សេងៗ

មាត្រា ២១.- ក.ស.ស អាចមានគណនីធនាគារ ក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយត្រូវប្រើប្រាស់គណនីនេះ សំរាប់ប្រតិបត្តិការរបស់ខ្លួន ។

មាត្រា ២២.- ជារៀងរាល់ឆ្នាំ ក្រោយពីការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រាក់ចំណេញ ដែល ក.ស.ស ទទួលបាន ក្រោយពីការបូកដកគ្រប់គណនីនៃការចំណាយរួចហើយ ដែលគេមិនទាន់ប្រើប្រាស់ ជាមូលនិធិត្រូវបញ្ចូលទៅក្នុងគណនីមូលនិធិបំរុងហិរញ្ញវត្ថុរបស់ ក.ស.ស ។

មាត្រា ២៣.- ការផ្ទេរប្រាក់ពីគណនីមួយ ទៅគណនី សំរាប់ប្រើប្រាស់ក្នុងការវិនិយោគ ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូក ៤

## ការទំនាក់ទំនងជាមួយរដ្ឋ

**មាត្រា ២៤.-** ក្នុងរយៈពេល១៥ ថ្ងៃយ៉ាងយូរបំផុត ក្រោយពេលការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ក.ស.ស ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួង សាធារណការ និងរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារដូចខាងក្រោម ។

-កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល

-តារាងតុល្យការ ដូចមានចែងក្នុងមាត្រា១៨ របាយការណ៍ស្តីពីលទ្ធផល-គណនេយ្យ និង គណនីគ្រប់គ្រងទាំងឡាយរបស់ ក.ស.ស

-របាយការណ៍របស់ស្នងការគណនី ។

**មាត្រា ២៥.-** ត្រូវបានដាក់ឱ្យនៅអម ក.ស.ស នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ ដែលត្រូវតែងតាំង ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈ ប៉ុន្តែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្ម ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រាទី២០ ទៅ ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

**មាត្រា ២៦.-** ក.ស.ស មានសិទ្ធិធ្វើកិច្ចការងារ ចំពោះអតិថិជន ឬអាជីវករឯកជន ដែលពុំស្របតាមកម្រៃថ្លៃឈ្នួលផ្សេងៗ តាមកិច្ចសន្យានិងកិច្ចព្រមព្រៀង ។

## ជំពូក ៥

## អវសានបញ្ញត្តិ

**មាត្រា ២៧.-** បទប្បញ្ញត្តិណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អភិបាលក្រុងព្រះសីហនុ អគ្គនាយកកំពង់ផែក្រុងព្រះសីហនុ ត្រូវអនុវត្តនូវអនុក្រឹត្យនេះ ។

www.pheakdeylaw.com

មាត្រា ២៨.- អនុក្រឹត្យនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រីទី១

សម្តេចនាយករដ្ឋមន្ត្រីទី២

ជ.រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន — ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច

រដ្ឋលេខាធិការ — និងហិរញ្ញវត្ថុ

ហត្ថលេខា — ហត្ថលេខា

ត្រាំ អ៊ីវតឹក — គាត ឈន់

★★★

# អនុក្រឹត្យ លេខ ៥១ អនក្រ.បក

## ស្តីពីការបង្កើតកំពង់ផែស្វយ័តភ្នំពេញ ក.ស.ត

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើ ដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន

www.pheakdeylaw.com